ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

AGRICULTURAL AND RURAL DEVELOPMENT BANK

# គម្រោងដំណាំ ប័រ

## (AVOCADO, AVOCATIER, AVOCAT)



គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃ អេ.អ.ឌី.ប៊ី , មករា ២០២២

# ដំណាំប័រ

ដំណាំឈើហូបផ្លែប័រ (ភាសាបារាំង អាវ៉ូកាចេរ Avocatier ឬ អាវ៉ូកាត់ Avocat) ឬ អាវ៉ូកាដូ (ភាសាអង់គ្លេស : Avocado) ជាផ្លែឈើមានកំណើតចេញពីអាមេរិកកណ្តាល ។

ប័រ ជារុក្ខជាតិនៅក្នុងអម្បូរ Lauraceae ស្ថិតក្នុងអម្បូរជាមួយ ផ្កាចន្ទន៍, ក្រវាញ និង Bay laurel ។

ប័រ ជាផ្លែឈើពាណិជ្ជកម្ម និងត្រូវបានដាំដុះនៅតំបន់ដែលមានអាកាសធាតុក្តៅទូទាំងពិភពលោក និងតំបន់ក្តៅមធ្យម។ ប័រ មានផ្លែពណ៌បៃតងពេលទុំបន្ទាប់ពីប្រមូលផល។ ដើមប័រអាចដាំដោយបណ្តុះគ្រាប់បាន និងអាចបង្កាត់ពូជគឺធ្វើតាមវិធីផ្សាំមែក ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងគុណភាពនិងបរិមាណផល ។

ផ្លែប័រខ្ចី យើងមិនអាចទទួលទានបានទេ ព្រោះវាមានសារជាតិ Tannin ធ្វើឱ្យមានរសជាតិល្វីង ញ៉ាំច្រើននឹងធ្វើឱ្យឈឺក្បាល យើងអាចទទួលបានតែផ្លែទុំ ដោយទទួលទានស្រស់ៗ។

**១-អត្ថប្រយោជន៍ចំពោះសុខភាពរាងកាយ:**

- ជាតិប្រេងនៅក្នុងសាច់ប័រ ជួយកាត់បន្ថយកម្រិត LDL-cholesterol ដែលជាកូឡេស្តេរ៉ូលមានផលប៉ះពាល់ចំពោះរាងកាយ និងបន្ថែមកម្រិត HDL-cholesterol នៅក្នុងឈាមដែលជាកូឡេស្តេរ៉ូលមានគុណសម្បត្តិល្អចំពោះរាងកាយ ។
- អាចបង្ការជំងឺបេះដូង
- អាចកាត់បន្ថយជាតិខ្លាញ់ក្នុងឈាម អ្នកជំងឺនេះខ្ពស់គួរទទួលទានផ្លែប័រ ។
- អាចជួយបញ្ចុះទម្ងន់ ព្រោះកាបូអ៊ីដ្រាតមានកម្រិតទាប និងដោយសារមានជាតិស្ករតិច ទើបអ្នកជំងឺទឹកនោមផ្អែមអាចទទួលទានផ្លែប័របានដែរ ។
- មានវីតាមីន A ដែលជាសារធាតុ Antioxidant ជួយការពារកោសិកាក្នុងរាងកាយពីសារធាតុពុលក្នុងខ្យល់ ទឹក និងចំណីអាហារ ហើយនិងជំនួយភ្នែក ។
- មានវីតាមីន B ជួយបង្ការជំងឺស្លឹកស្រពន់ និងជំងឺដំបៅមាត់ ។
- មានវីតាមីន C ជួយបង្ការជំងឺផ្តាសាយនិងឈាមតាមអញ្ចាញធ្មេញ ។
- ប័រសម្បូរទៅដោយសារធាតុរ៉ែ និងអាហារូបត្ថម្ភដែលចាំបាច់សម្រាប់រាងកាយ មិនថាជាកាល់ស្យូម, ប៉ូតាស្យូម, ផូស្វ័រ ដែលជួយកាត់បន្ថយកូឡេស្តេរ៉ូល ជាពិសេសហ្វូលិកជាអាហារសំខាន់សម្រាប់ស្ត្រីមានផ្ទៃពោះ ដោយសារហ្វូលិកជាអាហារូបត្ថម្ភចាំបាច់សម្រាប់ការលូតលាស់ ធំធាត់ និងបង្កើតជាលិការបស់ទារក ។
- និងអត្ថប្រយោជន៍ចំពោះសម្រស់ និងសុខភាពស្បែក, សក់...។ល។

## ២-លក្ខណៈរុក្ខសាស្ត្រ និងរុក្ខសាស្ត្រ

ប័រគឺជាដំណាំដែលងាយស៊ាំនិងប្រភេទដីសោះកក្រោះ ដីស្ងួតហួតហែង និងប្រភេទដីដែលក្បោះដីជាតិ។ នៅប្រទេសកម្ពុជាយើងខេត្តដែលសំបូរនិងនិយមដាំដំណាំប័រគឺមានខេត្តរតនៈគីរី និងមណ្ឌលគីរី។

ប័រអាចដាំបាននៅលើដីច្រើនប្រភេទ ប៉ុន្តែសមស្របបំផុតគឺនៅលើដីក្រហមបាសាល់ និងនៅតំបន់ខ្ពង់រាប។ គេតែងដាំដើមប័រនៅដើមរដូវវស្សាគឺចាប់ពីខែ ឧសភា ដល់ខែ កក្កដា។

ដោយសារតែប័រ ជាប្រភេទផ្លែឈើ ដែលមានសក្តានុពលខ្លាំងនៅលើទីផ្សារជាពិសេសប័រខ្មែរកំពុងតែទទួលបានការគាំទ្រច្រើនពីអ្នកប្រើប្រាស់ដោយអាចយកកសិផលនេះមកកែច្នៃជាបង្អែម ផ្លែឈើពេញនិយមងាយស្រួលលក់ មានតម្លៃខ្ពស់ ធ្វើឱ្យកសិករក្នុងស្រុកមានក្តីសង្ឃឹមនិងមមាញឹកក្នុងការពង្រីកដីដាំដុះបន្ថែមជាបន្តបន្ទាប់ផងដែរ។

**<u>ដើមប័រ</u>** ÷

ប័រ មានដើមត្រង់ កម្ពស់អាចដល់ទៅ ១៨ម៉ែត្រ សំបកពណ៌ត្នោតខ្ចី ហើយគ្រើមដូចស្បែកក្រពើ មានស្លឹកប័រមានពណ៌បៃតង ។ ផ្កាប័រមានទំហំតូចៗពណ៌សព្រលាំលឿង មាន ៦ ត្របកចេញជាកញ្ចុំពីចុងមែក ។

**<u>ផ្លែប័រ</u>** ÷

ផ្លែប័រមានរាងទ្រវែងឬមូល មានទាំងពូជសម្បកស្តើងនិងសម្បកក្រាស់ មានសាច់ម៉ដ្ឋ មានសម្បុរតាំងពីលឿងខ្ចីទៅដល់លឿងចាស់ គ្មានក្លិន មានគ្រាប់តែ ១ និងមានស្រោមស្រោបគ្រាប់ ។

**<u>ពូជប័រ</u>** ÷ មានដូចជា÷ Bacon, Fuerte, Gwen, Hass, Pinkerton, Reed, Stewart, Zutano, 034

១. ពូជគួទ័រម៉ាឡា (Guatemala) មានផ្លែពណ៌បៃតង ក្បាលផ្លែគ្រើម គ្រាប់មានទំហំតូច រាងមូល សាច់ក្រាស់ សម្បូរជាតិប្រេង ស័ក្តិសមនឹងអាកាសធាតុត្រជាក់បង្គួរ ។

២. ពូជឥណ្ឌាខាងលិច (West Indian) សម្បករលោងរងើមមានពណ៌បៃតងព្រលាំលឿង សាច់ក្រាស់ គ្រាប់នៅក្នុងស្រោមរលុង មានរសជាតិផ្អែមឡែមៗ មានជាតិប្រេងតិច ធន់នឹងអាកាសធាតុក្តៅ ។

៣. ពូជម៉ិកស៊ិកូ មានផ្លែតូចសម្បករលោងស្តើង ពេលចាស់មានពណ៌ស្វាយ ស្រោមស្រោបគ្រាប់ស្តើងនិងធំរលុង មានជាតិប្រេងច្រើន ធន់នឹងអាកាសធាតុត្រជាក់បានល្អ ។

### ៣. <u>ផ្ទៃដីដាំដុះ និងបរិមាណផលដំណាំប័រ</u>

តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ២០២០ នៅទូទាំងប្រទេសដំណាំប័រដាំដុះបាន ÷

| ល.រ | លក្ខណៈដាំដុះ | ផ្ទៃដីដាំដុះសរុប (ហិកតា) | ផ្ទៃដីដាំដុះទទួលផលសរុប(ហិកតា) | ទិន្នផលជាមធ្យម (តោន/ហិកតា) | បរិមាណផលសរុប (តោន) |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| ១ | លក្ខណៈគ្រួសារ | 556 | 378 | 12.17 | 4,596 |
| ២ | លក្ខណៈក្រុមហ៊ុន | 0 | 0 | 0 | 0 |
| | សរុប | 556 | 379 | 12.17 | 4,596 |

**៤.ការដាំដុះ និងរដូវកាល**

**៤-១)-ទីកន្លែងដាំដុះ**

-ប័រជាប្រភេទដំណាំងាយដាំស៊ុំនឹងតំបន់ដីស្ងួត ដីខ្សោះជីវជាតិជាដើម គេអាចដាំដើមប័របាននៅលើដីច្រើនប្រភេទប៉ុន្តែសមស្របបំផុតគឺលើដីក្រហមបាសាល់ជិតប្រភពទឹក ដីមិនដក់ទឹក និងដីទួលជម្រាល។ កសិករនិយមដាំដុះដើមប័រនៅដើមរដូវវស្សាចាប់ពីខែឧសភា ដល់ខែ កក្កដា។

**៤-២)-ការរៀបចំដី**

-ត្រូវពង្រាបដីឱ្យរាបស្មើ (ជីកប្រព័ន្ធរំដោះទឹក) បើតំបន់ដីទំនាបត្រូវលើករង ឬពូនគល់ឱ្យខ្ពស់។

**៤-៣)-ការជ្រើសរើសពូជ**

ពូជហាស (Hass) និងពូជប័រផ្លែវែងជាពូជប័រដែលមានសាច់រម្លូល គ្មានជាតិសរសៃក្នុងសាច់ដែលមិនបង្កអោយសាច់ប័រប្រែពណ៌ក្រម៉ៅពេលប៉ះទង្គិច សំបកមានលក្ខណៈរឹងក្រាស់ និងអាចរក្សាទុកបានយូរជាងប័រដ៏ទៃទៀត ផ្លែមានក្លិនឈ្ងុយ និងមានតម្លៃថ្លៃនៅលើទីផ្សារ។











Avocado - 034



Pinketon

ការដាំដើមប៉ំរមានវិធីជាច្រើនយ៉ាងដូចជា ÷ ការបណ្តុះគ្រាប់ ការបំបៅមែក ការផ្សាំដោយតមែកជាដើម។ល។ ការបណ្តុះគ្រាប់ និងការផ្សាំមែកកសិករមិនសូវនិយមទេ គេនិយមតែការផ្សាំដោយកាត់តមែកច្រើនជាងព្រោះវាមិនក្លាយ ឆាប់បានផល និងមានទិន្នផលខ្ពស់ (ដើមថ្មីមានឫសវែង តជាមួយមែកដែលឆាប់មានផ្លែ)។

**<u>ការជ្រើសរើសពូជ និងការសម្រាំងគ្រាប់</u>**÷

គ្រាប់ប៉ំរដែលត្រូវយកមកបណ្តុះគឺត្រូវតែជាគ្រាប់ទុំដោយធម្មជាតិ ។ គ្រាប់ប៉ំរទុំធម្មជាតិ ងាយស្រួលបណ្តុះ ងាយថែ មានរសជាតិល្វីងកម្រិតទាបហើយក៏ផ្តល់ផលច្រើនដែរ។ ករណីដែលកសិករមិនច្បាស់ថាតើគ្រាប់ប៉ំរនោះទុំល្អ ស្ទើរទុំ ឬខ្ចីទេនោះ កសិករអាចប្រើវិធីសាស្ត្រមួយទៀត គឺយកគ្រាប់ប៉ំរទៅបកសម្បកចេញឱ្យអស់រួចដាក់ត្រាំទឹករយៈពេល៣ថ្ងៃ។ ក្នុងរយៈពេល៣ថ្ងៃនេះ គេអាចប្តូរទឹក១ ឬ២ដង។ គ្រាប់ប៉ំរដែលល្អវានឹងលិច ឯគ្រាប់ប៉ំរដែលមិនល្អ វានឹងអណ្តែតឡើង ឬស្អុយ។ ដូច្នេះកសិករអាចរើសយកគ្រាប់ប៉ំរអណ្តែត និងស្អុយនោះចេញ ប៉ុន្តែគ្រាប់ប៉ំរដែលស្ងួតល្អខ្លះ ក៏អាចអណ្តែតឡើង ដូចគ្រាប់មិនល្អដែរ។

**<u>ការបណ្តុះកូន</u>** ÷

នៅពេលបណ្តុះប៉ំរ កសិករត្រូវកប់គ្រាប់ប៉ំរឱ្យលិចក្នុងដីតែពាក់កណ្តាលបានហើយ នៅពេលដំបូងៗត្រូវស្រោចទឹកដែលមានកម្រិត PH ៥ចុច តែម្តងប៉ុណ្ណោះ ក្នុងមួយថ្ងៃ ដើម្បីផ្តល់សំណើមដល់គ្រាប់ពូជងាយដុះ និងឆាប់លូតលាស់។ ប៉ុន្តែបើអាកាសធាតុក្តៅខ្លាំង កសិករអាចស្រោចទឹកពីរដងក្នុងមួយថ្ងៃ។

**<u>ការថែទាំកូនប៉ំរ</u>**÷ រយៈពេលដែលប៉ំរកំពុងលូតលាស់ រហូតដល់អាយុ៣ខែ កសិករត្រូវតាមដាន និងថែទាំតាមសម្រួល ដើម្បីឱ្យកូនប៉ំរលូតលាស់តាមដំណើរធម្មជាតិរបស់វា។ ការតាមដានការលូតលាស់ គឺដើម្បី ចៀងវាងកុំឱ្យមានមេរោគឆ្លង និងបញ្ហានានាលើកូនប៉ំរទាំងនោះ។

**៤-៤)-ការដាំដុះ**

-ការដាំដើមប៉ំរអាចដាំបានពីចន្លោះគុម្ពនីមួយៗ ពី ៥ម x ៥ម ឬរហូតដល់ ៨ម ឬ ៩ម

-ជីករណ្តៅទំហំ ០.៥ម x ០.៥០ម x ០.៥០ម ឬអាចធំជាងនេះក៏បាន



-សម្អាតស្មៅនៅជុំវិញគល់ឱ្យបានទៀងទាត់

-ដោតឈើជន្លង់ចងផ្កោបនិងកូនដើម និងការពារកំដៅថ្ងៃខ្លាំង

-រៀបចំប្រព័ន្ធទឹកស្រោចស្រពដំណាំឱ្យបានគ្រប់គ្រាន់

**៤-៥)-ការប្រើប្រាស់ជី**

-ដាក់ជីលាមកសត្វទ្រាប់បាត ចំនួន ១៥ ទៅ ២០គីឡូក្រាម និងដាក់បន្ថែមមេតំបែរជីវសាស្ត្រប៉ូតាស្យូម ០,៥គក្រ និងរោយកំបោរពី ០,៣ ទៅ ០,៥គក្រ/រណ្តៅ។

-ដើមប៉ររនៅតូចត្រូវដាក់ជីពី៤ទៅ ៥ដង/ឆ្នាំ។ បរិមាណដាក់ជីគឺអាស្រ័យទៅតាមអាយុកាលនៃដើម។

-នៅពេលដើមចាប់ផ្តើមចេញផ្លែកសិករត្រូវដាក់ជី កាល់លី (Kali) ខ្ពស់ជាងមុន។ បរិមាណដាក់ជីនឹងមានលុះនឹងនៅឆកនាំទី ៩ ទី១០។

-ចាំបាច់ត្រូវដាក់បន្ថែកំបោរ និងជីសរីរាង្គបាញ់បន្ថែមនូវបណ្ណាជីលើស្លឹកដូចជា÷ Alpha Super, Antonic ប្រើជី Grow More មុននិងក្រោយការដាក់ជីលើកទី៤។

<u>**កំណត់ចំណាំ**</u>÷ គោលការណ៍សំខាន់នៃការជំរុញឱ្យប៉រផ្តល់ទិន្នផលខ្ពស់

-ធ្វើឱ្យដីមានសុខភាពល្អ កាត់បន្ថយការប្រើប្រាស់ជី និងថ្នាំពុលនិងប្រើប្រាស់ជីធម្មជាតិឱ្យបានច្រើន

-ដើមត្រូវមានសុខភាពល្អ គ្មានការបុះផ្លាញពិសត្វល្អិតចង្រៃ និងជម្ងឺផ្សេងៗ។

-ប្រើផ្សិតជីវសាស្ត្រ ទ្រីកូឌែម៉ា ដើម្បីការពារ និងជម្រុញការលូតលាស់ កាន់ក្តិបបានច្រើន និងអាចបន្ថយការបំផ្លាញពីសត្វចង្រៃផ្សេងៗបាន។

**៤-៦)-ការស្រោចទឹក និងផ្អាប់គល់**

-ដើមប៉រត្រូវការទឹកក្នុងបរិមាណសមល្មម ប៉ុន្តែត្រូវស្រោចច្រើនដង។ គេអាចស្រោចទឹកពី ១០ ទៅ ១៥ថ្ងៃម្តងក្នុងរដូវប្រាំង គួបផ្សំនិងការផ្អាប់គល់ដោយមិនចាំបាច់ស្រោចទឹកជោគជាំនោះទេ។

**៤-៧)-របៀបបង្ការជម្ងឺ និងការកំចាត់ជន្ទច**

ដើមប៉រតែងត្រូវរងនូវជម្ងឺមួយចំនួនដូចជា÷

-ជម្ងឺរលួយឫស÷ ដើមប៉រមានជម្ងឺស្លឹកសោះអង្គើយ មែកងាប់បណ្តើរៗពីចុងដល់តួដើម។ កត្រូវរកឱ្យឃើញទាន់ពេលវេលានូវស្លាកស្នាមស្អុយទាំងនោះនៅលើដើមហើយកោសចេញឱ្យស្អាតនិងលាប sulfate ស្ពាន់កំបោរខាប់។ នៅពេលដើមងាប់ត្រូវដុតកំទេចចោលដើម្បីកុំឱ្យជម្ងឺឆ្លងរាលដាល។

-ជម្ងឺស្វិតស្រពោន÷ ស្លឹកស្វិតងាប់ ចាំបាច់ត្រូវប្រើថ្នាំ Anvil, Daconil, Aliette ដើម្បីបង្កាជម្ងឺ។

**៤-៨)-ការតាក់តែងមែក**

-ក្រោយពេលដាំរយៈពេលចាប់ពី ១ដល់ ៣ឆ្នាំត្រូវធ្វើការតាក់តែងមែកជាប្រចាំ

-កាត់មែកដែលមិនល្អចេញ (មែកដុះទេរខ្លាំង មែកលូតលាស់មិនល្អ មែកគងលើគ្នា..)

-ក្រោយពេលកាត់មែកចេញហើយត្រូវយកកំបោរលាបស្នាមកាត់ដើម្បីការពារមេរោគឆ្លង បន្ទាប់ពីកាត់មែករួចត្រូវបំផ្លាញរុក្ខាជាតិចង្រៃហើយជ្រុំដី និងដាក់ជីលាមកសត្វពី ១៥-៥០ គ.ក្រ/ ដើម ។

**៥)-<u>ការប្រមូលផល តម្លៃ និងទីផ្សារលក់ផលិតផលផ្លែប័រ</u>**

**៥-១)-ការប្រមូលផល**

-ប័រអាចចាប់ផ្តើមឱ្យផលលើកដំបូង ពីអាយុ ៤ ទៅ៥ឆ្នាំឡើងទៅបន្ទាប់ពីដាំ និងអាចបន្តផ្តល់ផលបានរហូតដល់ ២០ ទៅ ២៥ឆ្នាំ

-ប័រជាទូទៅអាចប្រមូលផលក្នុងចន្លោះខែ មិថុនា ដល់ ខែសីហា ឬយូរជាងនេះ

-ទិន្នផលចាប់ផ្តើមដំបូងពី ៣០ ទៅ ៧០គក្រ/ ដើម (ដើមប័រអាយុ ៤ឆ្នាំ-៥ឆ្នាំ) ដោយសារគេត្រូវកាត់ជម្រុះក្តិបចោលខ្លះដើម្បីកុំឱ្យបាក់មែក។

-ទិន្នផលអាចចាប់ពី ៤០០គក្រ/ ដើមនៅពេលដើមប័រអាយុចាប់ពី ១០ឆ្នាំឡើងទៅ

-អាយុកាលអាចផ្តល់ផលបានគឺរហូតដល់ ២៥-៣០ឆ្នាំ (កូនប័រដែលកាត់តមែក) ។

**៥-២)-ទីផ្សារលក់ផលិតផល និងតម្លៃ**

ទីផ្សារប័រខ្មែរមានការគាំទ្រយ៉ាងខ្លាំង ប៉ុន្តែអ្នកលក់មួយចំនួនបាននាំចូលផ្លែប័រពីប្រទេសវៀតណាម និងថៃ ដែលភាគច្រើនពុំមានគុណភាពល្អ ប្រសិនបើយើងនៅតែបណ្តោយឲ្យផលិតផលពីប្រទេសជិតខាងហូរចូលវាយលុកទីផ្សាររបស់ប្រជាកសិករច្រើនហួសហេតុពេកវានឹងនាំឲ្យកសិករខាតបង់ប្រាក់ចំណេញយ៉ាងច្រើនព្រោះការផលិតប័រនៅកម្ពុជាបានផ្តោតលើសុវត្ថិភាព និងគុណភាព។

ប្រសិនបើគ្មានការយកចិត្តទុកដាក់លើការលើកកម្ពស់ទីផ្សារផលិតផលប័រនោះទេវានឹងធ្វើកសិករបាក់ទឹកចិត្តដែលនាំឲ្យកសិករអាចនឹងបោះបង់ចោលអាជីពនេះ។កសិករយើងមិនទាន់អាចលក់ផលិតផលកសិកម្មក្នុងតម្លៃដើមទាបបាននៅឡើយទេ ព្រោះតម្លៃដើមផលិកម្មកសិកម្មខ្ពស់ហើយបច្ចេកទេសដាំក៏នៅមានកម្រិតផងដែរ។

សព្វថ្ងៃនេះមានឈ្មួញច្រើនណាស់ដែលចាំទទួលទិញទិន្នផលប័រយកទៅលក់បន្ត តម្លៃបោះដុំចេញពីចំការនៅឆ្នាំនេះ គឺចន្លោះពី ៥,០០០រៀល ទៅ ៧,០០០រៀល/គីឡូក្រាមទៅឲ្យឈ្មួញកណ្តាល ហើយគេលក់បន្តបានប្រហែលពី៨,០០០រៀល ទៅ១០,០០០រៀល /គីឡូក្រាម ។ផលិតផលប័រនៅឆ្នាំនេះអាចមានតិចជាងឆ្នាំមុន ព្រោះបញ្ហាបម្រែបម្រួលអាកាសធាតុដែលមិនអំណោយផលដល់ការដាំដុះ។

ដំណាំប័រចាប់ផ្តើមហុចផលពីឆ្នាំទី៤ ឡើងទៅហើយទិន្នផលនឹងកើនឡើងជារៀងរាល់ឆ្នាំបន្តបន្ទាប់ វីងផ្លែផ្ការបស់វប័រគឺចេញមកក្នុង១ឆ្នាំម្តង និងមានម្តងម្កាលចេញមក២ដង គេហៅថាចេញផ្លែខុសរដូវ ។

## ៦)-ថ្លៃដើមសម្រាប់ការដាំ និងការថែទាំដើមប៉ះចំនួន ១៨០ដើម/ហិកតា

(ករណីដាំចន្លោះដើម ៨ម x ៧ម និងមានដីចំការផ្ទាល់ខ្លួន)

(គិតជារៀល)

| | បរិយាយ | ឯកតា | ចំនួន | តម្លៃឯកតា | ចំណាយសរុប | ចំនួនសារវិលស់ | ចំណាយកាត់វិលស់ |
|---|---|---|---|---|---|---|---|
| | I-**ចំណាយលើការចាប់ផ្តើមដាំដំបូង** | | | | | | |
| | **ចំណាយប្រែប្រួល** | | | | **6,528,000** | | **6,528,000** |
| 1 | ថ្លៃភ្ជួររាស់ | ដង | 3 | 250,000 | 750,000 | 1 | 750,000 |
| 2 | ថ្លៃជីករណ្តៅ និងថ្លៃដាំ | រណ្តៅ | 180 | 8,000 | 1,440,000 | 1 | 1,440,000 |
| 3 | កូនប៉ះ | ដើម | 180 | 12,000 | 2,160,000 | 1 | 2,160,000 |
| 4 | ជីធម្មជាតិ ១៥គក្រ/រណ្តៅ x ១៨០រណ្តៅ | គក្រ | 2,700 | 500 | 1,350,000 | 1 | 1,350,000 |
| 5 | កំបោរស 0.5គក្រ/រណ្តៅ | គក្រ | 90 | 1,200 | 108,000 | 1 | 108,000 |
| 6 | ឈើជន្ទល់ និងរបាំងការពារខ្យល់ កំដៅ | ដើម | 180 | 2,000 | 360,000 | 1 | 360,000 |
| 7 | ថ្នាំសម្លាប់សត្វកណ្តៀរ ១គក្រ/រណ្តៅ | គក្រ | 180 | 2,000 | 360,000 | 1 | 360,000 |
| | **ចំណាយមិនប្រែប្រួល** | | | | **8,440,000** | | **1,528,000** |
| 8 | ប្រព័ន្ធទុយោទឹក (ប្រើប្រាស់ ៥ឆ្នាំ) | កំប្លេ | 1 | 1,600,000 | 1,600,000 | 5 | 320,000 |
| 9 | ជីកស្រះ /អាងទឹក (ប្រើប្រាស់ ១០ឆ្នាំ) | | 1 | 2,800,000 | 2,800,000 | 10 | 280,000 |
| 10 | ម៉ាស៊ីនបូមទឹក (រយៈពេលប្រើប្រាស់៥ឆ្នាំ) | កំប្លេ | 1 | 3,280,000 | 3,280,000 | 5 | 656,000 |
| 11 | ធុងបាញ់ថ្នាំ (រយៈពេលប្រើប្រាស់២ឆ្នាំ) | | 1 | 400,000 | 400,000 | 2 | 200,000 |
| 12 | ម៉ាស៊ីនកាត់ស្មៅ (ប្រើប្រាស់ ៥ឆ្នាំ) | | 1 | 360,000 | 360,000 | 5 | 72,000 |
| | subtotal I | | | | 14,968,000 | | 8,056,000 |
| | II-**ចំណាយលើការថែទាំឆ្នាំទី១** | | | | | | |
| 1 | ថ្នាំសម្លាប់សត្វល្អិត៣ខែម្តង | ដង | 4 | 100,000 | 400,000 | | 400,000 |
| 2 | ជីលាមកសត្វ៤ដង/ឆ្នាំ ម្តង២០គក្រ/ដើម | ការ៉ុង | 600 | 3,000 | 1,800,000 | | 1,800,000 |
| 3 | ពលកម្មកាត់ស្មៅ កាត់៦ដង/ឆ្នាំ | នាក់ដង | 12 | 40,000 | 480,000 | | 480,000 |
| 4 | ប្រេងកាត់ស្មៅ ៥លីត្រ/ថ្ងៃx២ថ្ងៃx៦ដង | លីត្រ | 60 | 3,200 | 192,000 | | 192,000 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 5 | ម៉ាស៊ូតបូមទឹក ស្រោចរយៈពេល៦ខែ១ខែ ស្រោច២ដង ម្តង ១០ល.=១២០ល. | លីត្រ | 120 | 3,200 | 384,000 | | 384,000 |
| 6 | ចំណាយកាត់រំលស់ប្រចាំឆ្នាំ | | | | 1,528,000 | | 1,528,000 |
| | subtotal II | | | | <u>4,784,000</u> | | <u>4,784,000</u> |
| | **III-ចំណាយលើការថែទាំឆ្នាំទី២**<br>ដូចគ្នានឹងឆ្នាំទី១ | | | | <u>4,784,000</u> | | <u>4,784,000</u> |
| | **IV-ចំណាយលើការថែទាំឆ្នាំទី៣**<br>ដូចគ្នានឹងឆ្នាំទី១ | | | | <u>4,784,000</u> | | <u>4,784,000</u> |
| | **V-ចំណាយលើការថែទាំឆ្នាំទី ៤ ជាឆ្នាំត្រូវប្រមូលផលជាលើកដំបូង** | | | | | | |
| 1 | ចំណាយថែទាំប្រចាំឆ្នាំ | | | | 4,784,000 | | 4,784,000 |
| 2 | កម្លាំងពលកម្មប្រមូលផល | នាក់ដើម | 180 | 8,000 | 1,440,000 | | 1,440,000 |
| 3 | ចំណាយដឹកជញ្ជូនផល | | | | 1,000,000 | | 1,000,000 |
| | subtotal V | | | | <u>7,224,000</u> | - | <u>7,224,000</u> |
| | **VI-ចំណាយសរុបទាំងលើការដាំដុះ និងការថែទាំដល់ឆ្នាំទី ៤** | | | | <u>36,544,000</u> | - | <u>29,632,000</u> |
| | **VII-ចំណូលពីការប្រមូលផលលើកទី១ នៅចុងឆ្នាំទី៤** | | | | | | |
| | ទិន្នផល 50គ.ក/ដើម x 180 ដើម = 9,000គ.កកាត់ចេញ10% ផ្លែតូចមិនគ្រប់ខ្នាត នៅសល់ 8,100គក្រ | | 8,100 | 5,000 | 40,500,000 | | 40,500,000 |
| | **VII-ចំណេញពីការលក់ផលលើកដំបូង នៅចុងឆ្នាំទី៤** | | | | <u>3,956,000</u> | - | <u>10,868,000</u> |

**៧.ទិន្នផល÷** ទិន្នផលមានការកើនឡើងជារៀងរាល់ឆ្នាំ ប៉័រក្នុង១ដើមគឺអាចទទួលផលនៅឆ្នាំដំបូងបានចន្លោះពី៣០ ទៅ៧០គីឡូ និងអាចកើនឡើងដល់រាប់រយគីឡូក្រោមអាស្រ័យលើអាយុកាលនៃដើមប៉័រ ។ ទិន្នផលអាចចាប់ពី ១០០គក្រ/ដើមឡើងទៅករណីដើមប៉័រមានអាយុចាប់ពី ៦ឆ្នាំឡើងទៅ ។

## ៨.តារាងសង្ខេប ចំណូល ចំណាយ លើការដាំដំណាំប័រ

| | បរិយាយ | ឯកតា | ចាប់ផ្តើម | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | ឆ្នាំទី៦ | ឆ្នាំទី៧ | ឆ្នាំទី៨ |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | **ទិន្នផល/ដើម** | គក្រ | | | | | 50 | 75 | 100 | 125 | 150 |
| 2 | **ទិន្នផលសរុប** | គក្រ | | | | | 9,000 | 13,500 | 18,000 | 22,500 | 27,000 |
| 3 | **ចំណូលសរុប** | លាន៛ | - | - | - | - | 45.00 | 67.50 | 90.00 | 112.50 | 135.00 |
| 4 | **ចំណាយសរុប** | លាន៛ | 14.97 | 4.78 | 4.78 | 4.78 | 7.22 | 7.22 | 7.22 | 7.22 | 7.22 |
| 5 | **ចំណេញសរុប** | លាន៛ | (14.97) | (4.78) | (4.78) | (4.78) | 37.78 | 60.28 | 82.78 | 105.28 | 127.78 |

***សំគាល់***÷ ករណីការកំណត់កំណើនទិន្នផលសុទ្ធប្រចាំឆ្នាំថេរ និងតម្លៃលក់ថេរ ៥,០០០រៀល/គក្រ

ករណីកសិករមានគំនិតក្នុងការធ្វើពិពិធកម្មកសិកម្ម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយទៅតាមស្ថានភាពទីផ្សារ និងស្ថានភាពតម្រូវការដើម្បីកសាងនូវចង្វាក់តម្លៃដែលមានលក្ខណៈប្រកួតប្រជែង សហគ្រិនកសិករអាចដាំដំណាំរួមផ្សំមួយចំនួននៅតាមចន្លោះដើមប័រ ដែលអាចទទួលបាននូវផលិតផលកសិកម្មដែលមានគុណភាពជាប់ជាប្រចាំហើយក្នុងពេលជាមួយគ្នា អាចបង្កើនសមត្ថភាពស្រូបយកនូវប្រាក់ចំណូលបន្ថែម និងសម្រេចស្តង់ដារគុណភាពដែលទីផ្សារត្រូវការ។

## ៩.បញ្ហាប្រឈម

- ផលិតផលប័រក្នុងស្រុកលក់ចេញមានតម្លៃថ្លៃជាងផ្លែប័រនាំចូលពីប្រទេសជិតខាង
- កសិករមួយចំនួនជាកសិករខ្នាតតូច ឬអ្នកដាំដុះជាលក្ខណៈគ្រួសារ ឬជាកំសាន្តតែប៉ុណ្ណោះ ដែលពួកគាត់ធ្វើការដាំដុះទៅតាមការយល់ឃើញឬដាំតាមយថាកម្ម ដោយមិនបានយកចិត្តទុកដាក់អនុវត្តតាមបច្ចេកទេសឱ្យបានត្រឹមត្រូវ។
- ការចំណាយវិនិយោគលើការដាំដុះ ថែទាំដំណាំប័រមានតម្លៃខ្ពស់ និងពិបាកថែទាំ
- មានការក្លែងបន្លំផលិតផលដើម ធ្វើឱ្យអ្នកទិញបរិភោគបាត់ទំនុកចិត្តលើផលិតផលក្នុងស្រុក

## ១០.ដំណោះស្រាយ

ដាំដំណាំប័រនៅកម្ពុជានាពេលបច្ចុប្បន្នកំពុងពេញនិយមដោយមានអតិថិជននៅក្នុងស្រុកជាច្រើនបានគាំទ្រទៅលើគុណភាព និងសុវត្ថិភាពរបស់ផលិតផលកម្ពុជាដូចនេះកសិករដាំប័រគួរតែអនុវត្តតាមលក្ខខណ្ឌនៃការដាំដំណាំតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវទើបអាចទទួលបានទិន្នផលល្អប្រសើរ។ ប្រសិនបើកសិករដាំជា

លក្ខណៈទ្រង់ទ្រាយធំឬច្រើនគ្រួសារត្រូវមានការចងក្រងជាសហគមន៍កសិករដំណាំប៉ រដែលអាចមានលទ្ធភាពទទួលបាននូវជំនួយបច្ចេកទេសដាំដុះ ទុនឥណទានវិនិយោគ និងទីផ្សារលក់ផលិតផល។

ទោះបីជាដំណាំនេះអាចទទួលបានប្រាក់ចំណូលខ្ពស់ក្តី ប៉ុន្តែតម្រូវឱ្យមានការវិនិយោគទុនច្រើន និងទាមទារការអនុវត្តបច្ចេសទេសត្រឹមត្រូវជាមួយនឹងការថែទាំយ៉ាងដិតដល់ទើបទទួលបានជោគជ័យ។

ដោយដំណាំដើមឈើហូបផ្លែក្នុងស្រុកកំពុងតែមានសក្តានុពលទីផ្សារនៅកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងត្រៀមរៀបចំដាក់ចេញនូវគោលនយោបាយមួយចំនួនដូចតទៅ÷

- រៀបចំផែនការ និងទិសដៅពង្រីកការដាំដំណាំឈើហូបផ្លែ ដែលមានសក្តានុពលសម្រាប់ទីផ្សារក្នុង និងក្រៅប្រទេស។
- បង្កើតស្ថានីយបង្កាត់ និងផលិតពូជដំណាំហូបផ្លែដែលពេញនិយមសម្រាប់ផ្គត់ផ្គង់ដល់កសិករដើម្បីងាយស្រួលដាក់លក់នៅលើផ្សារក្នុង និងក្រៅប្រទេស។
- អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីជួយសម្រួលដល់ខ្សែច្រវាក់ផលិតកម្មដំណាំប៉ រនិងដំណាំហូបផ្លែផ្សេងទៀត
- បណ្តុះបណ្តាលបច្ចេកទេសដាំដុះទំនើប រួមទាំងបច្ចេកទេសមុននិងក្រោយប្រមូលផលដល់អ្នកដាំដុះឱ្យស្របតាមស្តង់ដារសុវត្ថិភាព ឆ្លើយតបនឹងលក្ខខណ្ឌតម្រូវសម្រាប់ការនាំចេញ។
- ចងក្រងសហគមន៍ផលិតដំណាំប៉ រ និងដំណាំហូបផ្លែដើម្បីជំរុញផលិតកម្មស្របតាមស្តង់ដារនិងតម្រូវការទីផ្សារ។
- លើកទឹកចិត្តដល់វិស័យឯកជនក្នុងការបង្កើតការវិនិយោគ ដើម្បីជំរុញខ្សែច្រវាក់ផលិតកម្ម និងការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងជំរុញការនាំចេញទៅក្រៅប្រទេស ជាពិសេសទុនឥណទានពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មដែលជាធនាគាររដ្ឋបម្រើគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យកសិកម្ម។
- គួររៀបចំបង្កើតសហព័ន្ធកសិឧស្សាហកម្មកម្ពុជាដើម្បីគាំទ្រ លើកទឹកចិត្ត និងជំរុញការអភិវឌ្ឍវិស័យកសិកម្ម កសិឧស្សាហកម្ម និងកសិធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។